# ព័ត៌មានស្តីពីការចាក់វ៉ាក់សាំងណូវ៉ាវ៉ាក់ សម្រាប់ជនបរទេសដែលស្នាក់នៅក្នុងប្រទេសកូរ៉េ (អាយុចាប់ពី១៨ឆ្នាំឡើងទៅ)

អត្រានៃការចាក់វ៉ាក់សាំងសម្រាប់ជនបរទេសដើម្បីប្រឆាំងនឹងកូវីដ១៩ គឺទាបជាងប្រជាជនកូរ៉េខណៈពេលដែលអត្រានៃការឆ្លងក្នុងចំណោមជនបរទេសនាពេលថ្មីៗនេះមានកម្រិតខ្ពស់ ដូច្នេះសូមកុំភ្លេចចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដើម្បីជីវិតប្រកបដោយសុវត្ថិភាពនៅក្នុងប្រទេសកូរ៉េ។

**ជនបរទេសដែលមានអាយុលើសពី១៨ឆ្នាំ ដែលកំពុងស្នាក់នៅក្នុងប្រទេសកូរ៉េក្នុងរយៈពេលយូរ(លើសពី៩០ថ្ងៃ) គឺអាចទទួលបានការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ដោយឥតគិតថ្លៃ។**

- **វ៉ាក់សាំងណូវ៉ាវ៉ាក់(NVX)** គឺជាវ៉ាក់សាំងដែលផលិតដោយវិធីសាស្ត្រផ្សំប្រូតេអ៊ីនបែបបុរាណ ហើយវ៉ាក់សាំងផ្សេងៗដូចជាHPV និងវ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទB ត្រូវបានផលិតតាមរបៀបដូចគ្នា។ ជនបរទេសដែលមានអាយុលើសពី១៨ឆ្នាំ ហើយមិនទាន់ទទួលការចាក់វ៉ាក់សាំងលើកទី១ ទី២ និងទី៣ ដោយសារការព្រួយបារម្ភអំពីប្រតិកម្មមិនល្អចំពោះវ៉ាក់សាំងmRNA(ហ្វាយសឺរ, ម៉ូឌែណា)ជាដើមនោះគឺ **អាចទទួលចាក់វ៉ាក់សាំងណូវ៉ាវ៉ាក់ ចាប់ពីថ្ងៃទី១៤ ខែកុម្ភៈ។**

- មិនថាអ្នកមានការធានារ៉ាប់រងសុខភាពឬអត់នោះទេ អ្នកអាចទទួលវ៉ាក់សាំងណូវ៉ាវ៉ាក់ថ្នាំបង្ការកូវីដ១៩ នៅស្ថាប័នវេជ្ជសាស្ត្រឬមណ្ឌលសុខភាពសាធារណៈ។

- **វិធី កក់នឹងការចាក់ថ្នាំបង្ការ**

១) **ការចុះឈ្មោះជនបរទេស៖** អ្នកអាចធ្វើការកក់តាមអនឡាញ ឬតាមទូរស័ព្ទដោយប្រើលេខកាតសម្គាល់ចុះឈ្មោះជនបរទេសបាន។

* ការកក់ទុកមុនតាមអ៊ីនធឺណិត: ចូលទៅកាន់ប្រព័ន្ធកក់ទុកមុននៃការចាក់ថ្នាំបង្ការកូវីដ១៩(https://ncvr.kdca.go.kr) បន្ទាប់ពីផ្ទៀងផ្ទាត់សាមីខ្លួនហើយទើបអាចធ្វើការកក់បាន(ថ្ងៃទី២១ ខែកុម្ភៈ ~)→ទៅកាន់មណ្ឌលសុខភាពសាធារណៈ ឬស្ថាប័នវេជ្ជសាស្ត្រដែលបានទទួលសិទ្ធ ដើម្បីចាក់ថ្នាំបង្ការ (ថ្ងៃទី៧ ខែមីនា~)

** ការកក់តាមទូរស័ព្ទ ទទួលថ្នាំបង្ការនៅថ្ងៃកក់៖ ការចាក់វ៉ាក់សាំងណូវ៉ាវ៉ាក់ ធ្វើការកក់តាមទូរស័ព្ទទៅកាន់ស្ថាប័នវេជ្ជសាស្ត្រឬមណ្ឌលសុខភាពសាធារណៈ បន្ទាប់ពីបញ្ជាក់មានវ៉ាក់សាំងនៅសេសសល់(ថ្ងៃទី១៤ ខែកុម្ភៈ ~)→ទៅកាន់មណ្ឌលដោយផ្ទាល់ ហើយចាក់ថ្នាំបង្ការក្នុងថ្ងៃតែមួយ(ថ្ងៃទី១៤ ខែកុម្ភៈ ~)

២) **ជនបរទេសដែលមិនបានចុះឈ្មោះ (រួមទាំងអ្នកខុសច្បាប់)៖** អ្នកអាចទទួលបានលេខគ្រប់គ្រងបណ្តោះអាសន្នពីមណ្ឌលសុខភាពសាធារណៈ ហើយធ្វើការកក់តាមអ៊ីនធឺណេត(អ្នកកក់ជំនួស) ឬក៏កក់តាមទូរស័ព្ទបាន។

* ការកក់ទុកមុនតាមអ៊ីនធឺណិត(អ្នកកក់ជំនួស)៖ ចូលទៅកាន់ប្រព័ន្ធកក់ទុកមុននៃការចាក់វ៉ាក់សាំងកូវីដ១៩ (https://ncvr.kdca.go.kr) បន្ទាប់មកអ្នកកក់ជំនួស ធ្វើការផ្ទៀងផ្ទាត់ពីសាមីខ្លួនរួច ទើបអាចធ្វើការកក់បាន(ថ្ងៃទី២១ ខែកុម្ភៈ~)→មណ្ឌលសុខភាពសាធារណៈឬស្ថាប័នវេជ្ជសាស្ត្រដែលបានទទួលសិទ្ធ ចាក់វ៉ាក់សាំង(ថ្ងៃទី៧ ខែមីនា ~)

** ការកក់តាមទូរស័ព្ទទទួលថ្នាំបង្ការនៅថ្ងៃកក់៖ ការចាក់វ៉ាក់សាំងណូវ៉ាវ៉ាក់ ធ្វើការកក់តាមទូរស័ព្ទទៅកាន់ស្ថាប័នវេជ្ជសាស្ត្រឬមណ្ឌលសុខភាពសាធារណៈ បន្ទាប់ពីបញ្ជាក់មានវ៉ាក់សាំងនៅសេសសល់(ថ្ងៃទី១៤ ខែកុម្ភៈ~)→ ទៅកាន់មណ្ឌលដោយផ្ទាល់ ហើយចាក់ថ្នាំបង្ការក្នុងថ្ងៃតែមួយ(ថ្ងៃទី១៤ ខែកុម្ភៈ~)

*** នៅពេលចេញលេខគ្រប់គ្រងបណ្តោះអាសន្ន ករណីអ្នកមិនមានអត្តសញ្ញាណប័ណ្ណដែលមានសុពលភាពនោះអ្នកគ្រាន់តែមានមួយក្នុងចំណោម លេខទំនាក់ទំនង(សាមីខ្លួនឬអ្នកស្គាល់) រឺក៏អ៊ីមែលឬអាសយដ្ឋានលំនៅដ្ឋាន គឺអាចបានហើយ។

**៣) ចាក់ថ្នាំលើកទី៣ វ៉ាក់សាំងណូវ៉ាវ៉ាក់(NVX)**

* ការចាក់វ៉ាក់សាំង NVX ដូសទី៣ បន្ទាប់ពីចាក់ថ្នាំ NVX-NVX ៖ គឺអាចចាក់ថ្នាំបង្ការក្នុងថ្ងៃ កក់ទុកមុនតាមអ៊ីនធឺណេត និងការកក់តាមទូរស័ព្ទ។

** បន្ទាប់ពីការចាក់វ៉ាក់សាំងផ្សេងៗ(mRNA, AZ, J)រួច ករណីមានមូលហេតុសម្រាប់ការទប់ស្កាត់ ឬការពន្យារ ពេលចាក់វ៉ាក់សាំង ត្រូវយោងតាមការផ្តល់យោបល់របស់វេជ្ជបណ្ឌិតជាមុនសិនទើបអ្នកចាក់ដូសទី៣វ៉ាក់សាំងNVXបាន ៖ អាចចាក់វ៉ាក់សាំងបានតែក្នុងថ្ងៃដែលកក់តាមទូរស័ព្ទតែប៉ុណ្ណោះ។

※ ឯកសារយោង

- **ព័ត៌មានអំពីអត្តសញ្ញាណគឺ ត្រូវបានប្រើសម្រាប់គោលបំណងចាក់វ៉ាក់សាំងតែប៉ុណ្ណោះ, ក្រោមប្រពន្ធ័លើកលែងកាតព្វកិច្ចជូនដំណឹង ការពិតការស្នាក់នៅខុសច្បាប់ជាដើម មិនត្រូវបានជូនដំណឹងទៅការិយាល័យអន្តោប្រវេសន៍ឡើយ។**
- សម្រាប់ព័ត៌មានលំអិតផ្សេងៗសូមមើលក្នុងគេហទំព័ររបស់មជ្ឈមណ្ឌលជាតិគ្រប់គ្រងនិងការពារជំងឺនៃប្រទេសកូរ៉េ(KCDC) សម្រាប់ការចាក់វ៉ាក់សាំងកូវីដ-១៩ 누리집(https://ncv.kdca.go.kr)។

질병관리청